# ការបំរើគឺជាគុណសម្បត្តិដ៏ទេវភាព

អែលឌើរ ខាឡូស អេច អាម៉ាដូ
នៃក្រុម 70 នាក់

*ជនទាំងឡាយដែលបំរើនឹងព្យាយាមដើម្បីធ្វើឱ្យថ្លៃថ្នូរ បង្រួបបង្រួម និងលើកស្ទួយមនុស្សដទៃទៀត ។*

អ្វី ៗដែលព្រះយេស៊ូវបានធ្វើសំរាប់សេចក្ដីសង្គ្រោះរបស់យើងគឺពិសេសណាស់ ។ ទ្រង់អាចសម្ដែងការប្រោសលោះរបស់ទ្រង់ ក្នុងរយៈពេលប្រមាណជាបីឆ្នាំនៃការបំរើរបស់ទ្រង់ ។ នៅថ្ងៃនេះ ខ្ញុំសូមជ្រើសរើសយកគោលបំណងបីសំរាប់ ជីវិតនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះ ។

## 1. ការបូជាដ៏ធួនរបស់ទ្រង់

គោលបំណងដំបូង និងមហិមាបំផុតគឺពិសេស ហើយជាការចាត់តាំងដ៏អស្ចារ្យ ដែលទ្រង់បានទទួលមកពីព្រះវរបិតារបស់ទ្រង់ៈ ដើម្បីអនុវត្តនូវការបូជាមួយដ៏និរន្តរ៍ និងអស់កល្បជានិច្ចសំរាប់មនុស្សលោក ។

នៅពេលដែលព្រះរាជបុត្រាបង្កើតតែមួយរបស់ព្រះវរបិតាសួគ៌ខាងសាច់ឈាម ទ្រង់បានទទួលបាននូវគុណសម្បត្តិដ៏ទេវភាពទាំងអស់របស់ព្រះវរបិតារបស់ទ្រង់ ហើយមកពី ម៉ារ៉ា ម្ដាយខាងលោកិយរបស់ទ្រង់ ទ្រង់បានទទួលបុគ្គលិកលក្ខណៈខាងជីវិតរមែងស្លាប់ ។

មានតែការបូជារបស់ទ្រង់ប៉ុណ្ណោះដែលអាចសង្គ្រោះយើងពីមតភាព និងស្ថានភាពធ្លាក់ចុះ (សូមមើលអាលម៉ា 34:8--14) ។ ទ្រង់បានយាងមកពិភពលោក ដោយមានគោលបំណងជាក់លាក់ដើម្បីពលិកម្មជីវិតរបស់ទ្រង់ ដោយសារមានតែជីវិតរបស់ទ្រង់ប៉ុណ្ណោះ ដែលអាចប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។

គ្មានមនុស្សណាម្នាក់ផ្សេងទៀត នៅពីអតីតកាល បច្ចុប្បន្នកាល ឬអនាគតកាលនៃការរស់នៅលើផែនដីដែលបានរស់នៅ ឬនឹងរស់នៅ ដើម្បីអនុវត្តនូវដង្វាយធួនសំរាប់អំពើបាបរបស់យើងឡើយ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះ និងជាព្រះប្រោសលោះរបស់យើង (សូមមើល យ៉ូហាន 3:16) ។

ទ្រង់នឹងត្រឡប់មកវិញម្ដងទៀតដើម្បីដឹកនាំ និងគ្រប់គ្រងនៅក្នុងចំណោមយើងជាមួយនឹងព្រះចេស្ដា និងសិរីរុងរឿងដ៏មហិមា ។

## 2. គោលលទ្ធិរបស់ទ្រង់

គោលបំណងទីពីរសំរាប់ការគង់នៅរបស់ទ្រង់ក្នុងចំណោមពួកយើង គឺដើម្បីបង្រៀនគោលលទ្ធិដែលទ្រង់បានរៀនមកពីព្រះវរបិតារបស់ទ្រង់ ដែលរួមមានទាំងពិធីបរិសុទ្ធ ហើយសេចក្ដីសញ្ញាទាំងឡាយនៃសេចក្ដីសង្គ្រោះ និងការលើកដំកើង (សូមមើល ម៉ាកុស 1:27 យ៉ូហាន 7:16) ។

គោលលទ្ធិរបស់ទ្រង់គឺជាសេចក្ដីស្រឡាញ់ ការអភ័យទោស និងសេចក្ដីមេត្តាករុណា ។ វាគឺជាមធ្យោបាយដើម្បីរស់នៅក្នុងសេចក្ដីសុខសាន្ត និងសុខដុមនៅក្នុងចំណោមមនុស្សលោក និងមធ្យោបាយដើម្បីត្រឡប់ទៅរស់នៅជាមួយព្រះវិញ ។

**3. ការបំរើរបស់ទ្រង់ចំពោះកូនចៅនៃព្រះ**

គោលបំណងទីបីរបស់ទ្រង់គឺដើម្បីស្ថាបនានូវនគរ ដោយការបំរើដល់អ្នកដទៃ។ នេះគឺជាប្រភេទខុសប្លែកមួយនៃភាពជាអ្នកដឹកនាំ។ ការបំរើគឺជាបុគ្គលិកលក្ខណៈនៃពួកសិស្សរបស់ទ្រង់---ជាគុណសម្បត្តិដ៏ទេវភាព។

"អ្នករាល់គ្នាហៅខ្ញុំជាលោកគ្រូ ហើយជាព្រះអម្ចាស់ នោះក៏ត្រូវមែន ពីព្រោះគឺខ្ញុំនេះហើយ។ ដូច្នេះបើខ្ញុំដែលជាព្រះអម្ចាស់ ហើយជាគ្រូបានលាងជើងឱ្យអ្នករាល់គ្នា នោះគួរតែឱ្យអ្នករាល់គ្នា លាងជើងដល់គ្នានឹងគ្នាដែរ។ ត្បិតខ្ញុំបានធ្វើដំរាប់ទុកឱ្យអ្នករាល់គ្នាហើយ ដើម្បីឱ្យអ្នករាល់គ្នាត្រាប់តាមការដែលខ្ញុំបានធ្វើឱ្យនោះ" (យ៉ូហាន 13:13--15)។

ទ្រង់បានរស់នៅដើម្បីផ្សព្វផ្សាយដំណឹងល្អនៃនគរ ហើយដើម្បីព្យាបាលជម្ងឺគ្រប់ប្រភេទទាំងអស់ (សូមមើល ម៉ាថាយ 4:23--24)។ ដើម្បីបង្រៀនគោលលទ្ធិរបស់ទ្រង់ និងបំរើដល់មិត្តភក្តិរបស់យើងគឺជាការទទួលខុសត្រូវពីរយ៉ាង ដែលយើងបានទទួលយក នៅពេលយើងធ្វើបុណ្យជ្រមុជទឹក។ ការណ៍នេះបានផ្លាស់ប្រែចិត្តជឿដល់យើងទៅជាអ្នកបំរើដ៏ពិតប្រាកដរបស់ព្រះគ្រីស្ទ។

នៅក្នុងឱកាសមួយ បន្ទាប់ពីបង្រៀនគោលលទ្ធិរបស់ទ្រង់ ទ្រង់បានមានសេចក្តីអាណិតអាសូរដល់ប្រជាជន ហើយបានសម្តែងនូវអព្ភូតហេតុនៃការកាច់នំបុ័ងប្រទានដល់ពួកសិស្ស គេក៏ចែកដល់ហ្វូងមនុស្ស ដោយបើកសម្តែងដល់យើងនូវបុគ្គលិកលក្ខណៈនៃសេចក្តីអាណិតអាសូរ និងការបំរើរបស់ទ្រង់។ នៅថ្ងៃបន្ទាប់ ហ្វូងមនុស្សមកកាន់តែច្រើនជាងមុន ពីព្រោះអាហារដែលពួកគេបានទទួល។ ទ្រង់បានបង្រៀនពួកគេជាមួយនឹងការប្តេជ្ញាចិត្ត និងការនិមិត្តដ៏នៅអស់កល្បជានិច្ច។

"អ្នករាល់គ្នារកខ្ញុំ មិនមែនដោយព្រោះបានឃើញទីសំគាល់ទេ គឺដោយព្រោះតែបានបរិភោគនំបុ័ងឆ្អែតប៉ុណ្ណោះ។ កុំឱ្យខំប្រឹងឱ្យបានតែអាហារដែលតែងតែពុករលួយនោះឡើយ ចូរខំឱ្យបានអាហារដែលនៅស្ថិតស្ថេរដរាបដល់ជីវិតអស់កល្បជានិច្ចវិញ" (យ៉ូហាន 6:26--27)។

ក្នុងនាមជាសាសនាចក្រ យើងគួរតែឱ្យចំណីដល់អ្នកដែលឃ្លាន ព្យាបាលដល់អ្នកជម្ងឺ ស្លៀកពាក់ឱ្យអ្នកអាក្រាត ហើយផ្តល់ជំរកដល់ជនទុរគតិ។ ជាមួយនឹងដង្វាយតមអាហារយើងសំរាលដល់នូវសេចក្តីត្រូវការចម្បង និងភ្លាមៗនៃសមាជិកទាំងឡាយ ហើយជាមួយនឹងផែនការនៃសុខុមាលភាព យើងជួយដល់តំរូវការយូរអង្វែងរបស់ពួកគេ។ នៅពេលដែលមានគ្រោះធម្មជាតិ តាមរយៈសេវាកម្មសប្បុរសធម៌ យើងផ្តល់ឱ្យនូវជំនួយដល់បងប្អូនប្រុសស្រីរបស់យើង ដែលមិនមានជំនឿដូចយើង។

ដោយគ្មានការធ្វេសប្រហែសនូវសេចក្តីត្រូវការខាងលោកិយទាំងនេះ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ តាមរយៈបទបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ រក្សានូវភាពខ្ពង់ខ្ពស់បំផុត និងពលិកម្មនៃការបំរើដ៏ថ្លៃថ្លា គឺដើម្បីប្រសិទ្ធពរជ័យដល់មនុស្សទាំងអស់ ដោយការបង្រៀនពួកគេនូវគោលលទ្ធិនៃព្រះគ្រីស្ទ និងការអញ្ជើញពួកគេដើម្បីទទួលពិធីការសង្គ្រោះទាំងឡាយ ដើម្បីពួកគេអាចទទួលបាន "អតមភាព និងជីវិតដ៏នៅអស់កល្បជានិច្ច" (ម៉ូសេ 1:39)។

*ការផ្លាស់ប្តូរគំនិត និងអាកប្បកិរិយា*

ខ្ញុំដឹងថាព្រះស្រឡាញ់យើង។ ទ្រង់អនុញ្ញាតឱ្យយើងអនុវត្តសេរីភាពជ្រើសរើសខាងសីលធម៌របស់យើង

ទោះបីជានៅពេលដែលយើងធ្វើខុស។ ទ្រង់អនុញ្ញាតឱ្យយើងធ្វើការសំរេចចិត្តរបស់យើងផ្ទាល់ខ្លួន។

ព្រះគ្រីស្ទមិនអាចជួយយើងទេ បើយើងមិនទុកចិត្តនៅលើទ្រង់ ទ្រង់មិនអាចបង្រៀនយើងទេ បើយើងមិនបំរើដល់ទ្រង់ ។ ទ្រង់នឹងមិនបង្ខិតបង្ខំយើងឱ្យធ្វើអ្វីដែលត្រូវទេ ប៉ុន្តែទ្រង់នឹងបង្ហាញផ្លូវដល់យើង នៅពេលយើងសំរេចចិត្តដើម្បី បំរើទ្រង់តែប៉ុណ្ណោះ។ ពិតប្រាកដណាស់ សំរាប់យើងបំរើនៅនគររបស់ទ្រង់ ព្រះគ្រីស្ទតំរូវថាយើងទទួលបទពិសោធន៍នៃការផ្លាស់ប្តូរគំនិត និងអាកប្បកិរិយា។

"ត្បិតតើមនុស្សនឹងស្គាល់ចៅហ្វាយដែលខ្លួនពុំដែលបានបំរើនោះ ហើយដែលជាអ្នកចម្លែកចំពោះមនុស្សនោះ ហើយនៅឆ្ងាយសតិអារម្មណ៍ និងបំណងនៃដួងចិត្តខ្លួនដូចម្តេចបាន?" (ម៉ូសាយ 5:13)។

*ពរជ័យនៃការបំរើ*

ខ្ញុំសូមថ្លែងទីបន្ទាល់ថា តាមរយៈការបំរើដល់ប្អូនរបស់យើង នោះយើងចាប់ផ្តើមស្គាល់ព្រះអម្ចាស់។ ការបំរើធ្វើឱ្យយើងរឹងមាំនៅក្នុងសេចក្តីជំនឿរបស់យើង ហើយមានអត្ថប្រយោជន៍នៅក្នុងនគររបស់ទ្រង់។ ការបំរើផ្តល់ឱ្យយើងនូវគោលបំណង និងសេចក្តីក្លាហាននៅក្នុងជីវិត។ វាធ្វើឱ្យយើងកាន់តែចូលទៅជិតព្រះ និងជួយយើងឱ្យកាន់តែល្អខាងនិស្ស័យដ៏ទេវភាពរបស់យើង។ វាបង្រៀនយើងឱ្យស្រឡាញ់ និងយល់ពីបងប្អូនរបស់យើង ហើយវាជួយយើងបំភ្លេចអំពីបំណងប្រាថ្នារបស់យើងផ្ទាល់ ដោយបោះបង់ចោលភាពអត្មានិយម អំនួត និងការមិនមានអំណរគុណ។ វាបង្រៀនយើងពីសេចក្តីត្រូវការនៃអ្នកដទៃ ដែលអនុញ្ញាតឱ្យយើងអភិវឌ្ឍគុណធម៌ ដែលព្រះអង្គសង្គ្រោះមាន។

សេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់ សេចក្តីអត់ធ្មត់ ការយល់ចិត្ត និងសាមគ្គីភាពនឹងកើនឡើងនៅពេលយើងបំរើ ខណៈដែលការមិនចេះអត់ឱនគ្នា ការប្រច័ណ្ឌ ការច្រណែន សេចក្តីលោភ និងភាពអត្មានិយមត្រូវថយចុះ ឬសាបសូន្យ។ ដរាបណាយើងកាន់តែផ្តល់ឱ្យ ដរាបនោះយើងនឹងមានសមត្ថភាពក្នុងការបំរើ ការយល់ចិត្ត និងសេចក្តីស្រឡាញ់ ហើយនឹងរីកចំរើនឡើង។

ជនទាំងឡាយណាដែលបំរើនឹងស្វែងរកការសព្វព្រះទ័យពីព្រះជានិច្ច ហើយរស់នៅយ៉ាងសុខដុមជាមួយទ្រង់។ ពួកគេនឹងពោរពេញដោយសេចក្តីសុខសាន្ត ពួកគេនឹងមាននូវទឹកមុខរីករាយ ហើយវិញ្ញាណនៃសេចក្តីមេត្តាករុណា។

ជនទាំងឡាយណាដែលបំរើនឹងព្យាយាមដើម្បីធ្វើឱ្យកាន់តែថ្លៃថ្នូរ ស្ថាបនា និងលើកស្ទួយបងប្អូនរបស់ពួកគេ ហេតុដូច្នោះហើយ ពួកគេនឹងស្វែងរកសេចក្តីល្អនៅក្នុងអ្នកដទៃ ហើយពួកគេនឹងមិនស្វែងរកមូលហេតុ ឬមានពេលដើម្បីអាក់អន់ចិត្តនោះទេ។ ពួកគេអភិវឌ្ឍគុណធម៌សំរាប់ជនទាំងឡាយណាដែលរិះគន់ដល់ពួកគេ។ ពួកគេមិនរំពឹងទុកនូវប្រជាប្រិយភាព ឬរង្វាន់នោះទេ។ ពួកគេមាននូវសេចក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទ។

ជនទាំងឡាយណាដែលបំរើនឹងមានឆន្ទៈដើម្បីចែកចាយជានិច្ច នូវអ្វីដែលពួកគេមាន និងអ្វីដែលពួកគេដឹងនៅគ្រប់ពេលទាំងអស់ នៅគ្រប់កន្លែងទាំងអស់ និងជាមួយមនុស្សទាំងអស់។

ជនទាំងឡាយណាដែលបំរើសូម្បីតែនៅក្នុងគ្រាដ៏លំបាកនឹងទទួលបាននូវសេចក្តីសង្ឃឹមដែលរស់រវើកក្នុងអនាគតដ៏ប្រសើរជាង។ ពួកគេនឹងបន្តរឹងមាំនៅកណ្តាលការរិះគន់ ពីព្រោះតែសេចក្តីសង្ឃឹមរបស់ពួកគេនៅលើព្រះគ្រីស្ទ។

ជនទាំងឡាយណាដែលនឹងទទួលយកនូវការចាត់តាំងរបស់ពួកគេជាមួយនឹងសេចក្តីរាបទាប ដោយស្គាល់នូវដែនកំណត់របស់ពួកគេ ប៉ុន្តែបានត្រូវធ្វើឱ្យជឿថា មនុស្សពីរនាក់អាចធ្វើអ្វីៗបានទាំងអស់ដែលពួកគេស្នើឱ្យធ្វើ ដរាបណាមនុស្សម្នាក់នៅក្នុងចំណោមមនុស្សពីរនាក់នោះគឺជាព្រះ។

ជាមួយនឹងការបំផុសគំនិតដ៏ទេវភាព ស្តេចបេនយ៉ាមីន បានប្រកាសថា៖ "កាលណាអ្នករាល់គ្នានៅក្នុងការបំរើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបំរើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ" (ម៉ូសាយ 2:17)។ ជនទាំងឡាយណាដែលបំរើនឹងមានការយល់ដឹងយ៉ាងមហិមាពីបុគ្គលិកលក្ខណៈ និងអាកប្បកិរិយារបស់ព្រះ។

ជនទាំងឡាយណាដែលបំរើដោយការពលិកម្ម សូម្បីតែនៅពេលអ្វីៗមិនកើតឡើងតាមអ្វីដែលពួកគេចង់បានក្តី គឺមិនងាយនឹងបាក់ទឹកចិត្ត ឬមួម៉ៅឡើយ ពីព្រោះសេចក្តីសន្យានៃសេចក្តីសុខសាន្តនៃគំនិត និងភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធនឹងមិនបោះបង់ចោលពួកគេឡើយ។

*ការបំរើទូទាំងពិភពលោក និងក្នុងមូលដ្ឋាន*

នៅក្នុងសាសនាចក្រ មានសមាជិករាប់ម៉ឺននាក់ ដែលបំរើដោយមិនគិតពីខ្លួនឯងនៅក្នុងប្រទេសជាង 170 នៅក្នុងភាសាចំរុះជាច្រើន។ ពួកគេបានផ្តល់ការបំរើដោយមិនគិតពីខ្លួនឯង តាមរយៈភាពជាអ្នកដឹកនាំ ការបង្រៀន និងការថែរក្សាចំពោះអ្នកដទៃ ដោយគ្មានប្រាក់ខែ ឬសម្ភារជារង្វាន់ ដោយគ្មានទះដៃអបអរ ឬមានប្រជាប្រិយភាពទូទាំងពិភពលោកនោះទេ។ ពួកគេផ្តល់ឱ្យនូវពេលវេលារបស់ពួកគេ ទេពកោសល្យរបស់ពួកគេ និងធនធានរបស់ពួកគេ ពួកគេលះបង់អ្វីៗដែលពួកគេមាន ហើយបំរើយ៉ាងមានប្រសិទ្ធភាព និងយ៉ាងអស្ចារ្យ។ បន្ទាប់ពីពេលវេលាមួយ ពួកគេត្រូវបានដោះលែងឱ្យរួចពីកាតព្វកិច្ច ដើម្បីផ្តល់ឱកាសបំរើដល់អ្នកដទៃទៀត។ ពីព្រោះតែគោលលទ្ធិរបស់ទ្រង់ និងការបំរើរបស់ទ្រង់ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលបានស្តារឡើងវិញ កំពុងតែប្រទានពរដល់ជីវិតសមាជិកជានិច្ច។ យើងសូមអរគុណព្រះសំរាប់អ្នកទាំងអស់គ្នាដែលជាពួកបរិសុទ្ធដ៏ស្មោះត្រង់ ដែលបានទទួលនូវសេចក្តីអំណរនៃការបំរើ និងអធិស្ឋានថា ព្រះនឹងប្រទានពរដល់អ្នកជានិច្ច ដោយសារតែការបំរើ។ នៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។